ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

ឆ្នាំទី ០៥ លេខ ០១

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

# សកម្មភាព ការងារ

ECOSOCC

កសវ



# Work Activities

ប្រចាំខែមករា ឆ្នាំ២០១៨



# មាតិកាអត្ថបទ

## កិច្ចប្រជុំជំនាញបច្ចេកទេស រវាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្រុមប្រឹក្សាអ្នកច្បាប់ និងតំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល


| ល.រ | ឈ្មោះអត្ថបទ | លេខទំព័រ |
|---|---|---|
| ១- | កិច្ចប្រជុំជំនាញបច្ចេកទេសសាឡើងវិញលើសេចក្ដីព្រាងច្បាប់ស្ដីពីធានារ៉ាប់រង | ១ |
| ២- | កិច្ចប្រជុំជំនាញបច្ចេកទេសសាឡើងវិញលើសេចក្ដីព្រាងច្បាប់ស្ដីពីផ្លូវថ្នល់ | ២ |
| ៣- | ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជាប្រចាំខែវិច្ឆិកា ឆ្នាំ២០១១ | ៣ |
| ៤- | សកម្មភាពដទៃទៀតរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | ១០ |

# កិច្ចប្រជុំជំនាញបច្ចេកទេសសាឡើងវិញលើ សេចក្តីព្រាងច្បាប់ស្តីពីធានារ៉ាប់រង



កាលពីថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១១ និងថ្ងៃទី៤ ទី៥ ខែមករា ឆ្នាំ២០១២ វេលាម៉ោង ៨:៣០នាទី និងម៉ោង ១៥:០០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **យូឃាង ថាវរិទ្ធ** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និង ឯកឧត្តម **អ៊ុំ ម៉ុនធឿន** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាឡើងវិញលើ**សេចក្តីព្រាងច្បាប់ស្តីពីធានារ៉ាប់រង** ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិកអគ្គលេខាធិការរង និងមន្ត្រីនៃក.ស.វ. សមាជិក និងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** មន្ត្រីជំនាញនៃទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

សូមរំឭកថាសេចក្តីព្រាងច្បាប់ស្តីពីធានារ៉ាប់រងត្រូវបានដាក់ប្រជុំជំនាញបច្ចេកទេសលើកដំបូងតាំងពីថ្ងៃទី៣ ខែមីនា ឆ្នាំ២០១០ មកម្ល៉េះ ហើយធ្លាប់ឆ្លងកាត់កិច្ចប្រជុំចង្អៀតរវាង ECOSOCC ក្រុមប្រឹក្សាអ្នកច្បាប់ និងសាមីក្រសួង នឹងធ្លាប់ឆ្លងកាត់ក្រុមការងារក្រសួងយុត្តិធម៌ផងដែរ ដើម្បីកែសម្រួលលើចំណុចមួយចំនួន។

អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាឡើងវិញលើសេចក្តីព្រាងច្បាប់ធានារ៉ាប់រងដែលបានកែសម្រួលថ្មីនេះ ដោយផុលផុសនិងយកចិត្តទុកដាក់។ មាត្រាមួយចំនួនមានការពិភាក្សាគ្នាយ៉ាងច្រើនដូចជាមាត្រា៣៣ និងមាត្រា៣៩ ដែលជាលទ្ធផលបានឯកភាពកែសម្រួលមាត្រា៣៣ទៅជា រូបវន្តបុគ្គល ឬនីតិបុគ្គលជាម្ចាស់យានយន្តដែលប្រកបអាជីវកម្ម~~ត្រូវមានធានារ៉ាប់រងជាកាតព្វកិច្ច ហើយដែលធ្វើចរាចរលើផ្លូវថ្នល់សាធារណៈ~~នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវមានធានារ៉ាប់រងយានយន្តរបស់ខ្លួនពីក្រុមហ៊ុនធានារ៉ាប់រងណាមួយលើភារៈទទួលខុសត្រូវចំពោះការខូចខាតបង្កឡើងដោយតតិយជន ~~យានយន្តពីក្រុមហ៊ុនធានារ៉ាប់រងណាមួយចំពោះការរងរបួសដល់រូបរាងកាយ និង/ឬមរណភាព~~ដែលបណ្តាលមកពីសកម្មភាពនៃយានយន្តរបស់ខ្លួនទាំងរុឺម៉កសណ្តោងគ្រប់~~ប្រភេទបង្កឡើងដល់តតិយជន~~។

~~ការធានារ៉ាប់រងនេះ មិនត្រឹមតែមានប្រសិទ្ធភាពចំពោះម្ចាស់យានយន្តប៉ុណ្ណោះទេ ប៉ុន្តែត្រូវមានផងដែរចំពោះអ្នកបើកបរ និងអ្នកកាន់កាប់ថែទាំយានយន្ត~~។ ប្រភេទយានយន្តប្រកបអាជីវកម្មដែលត្រូវមានធានារ៉ាប់រងជាកាតព្វកិច្ច ត្រូវកំណត់ដោយអនុក្រឹត្យ។

ការធានារ៉ាប់រងជាកាតព្វកិច្ចនេះ ត្រូវមានប្រសិទ្ធភាពអនុវត្តផងដែរចំពោះអ្នកបើកបរ និងអ្នកដែលត្រូវបានផ្តល់សិទ្ធិឲ្យប្រើប្រាស់យានយន្ត។ ចំណែកឯមាត្រា៣៩ ត្រូវបានលុបចោល ~~ការធានារ៉ាប់រងជាកាតព្វកិច្ចផ្សេងៗទៀតត្រូវកំណត់ដោយអនុក្រឹត្យ~~។ ក្រៅពីមាត្រាពីរនេះក៏មានមាត្រាជាច្រើនទៀត ដែលអង្គប្រជុំបានពិភាក្សាគ្នាយ៉ាងផុលផុស ហើយបានសម្រេចកែសម្រួលពាក្យពេចន៍ ឃ្លាប្រយោគ ដើម្បីឲ្យកាន់តែល្អប្រសើរ។

អង្គប្រជុំជំនាញបច្ចេកទេសបានបញ្ចប់ការពិភាក្សាលើសេចក្តីព្រាងឯកសារនេះ ដោយទុកជំពូកទី១១ ទោសប្បញ្ញត្តិឲ្យក្រសួងសាមីយកទៅពិភាក្សាជាមួយក្រសួងយុត្តិធម៌៕

## កិច្ចប្រជុំជំនាញបច្ចេកទេសសាឡើងវិញលើ

# សេចក្តីព្រាងច្បាប់ស្តីពីផ្លូវថ្នល់



កាលពីថ្ងៃទី១ ថ្ងៃទី២ ថ្ងៃទី៨ ថ្ងៃទី៣១ ខែមករា និងថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០១២ នៅទីស្តីការគណៈរដ្ឋមន្ត្រីមានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **ឌុយ ឆៅ** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និង ឯកឧត្តម **ឡាំ ជា** អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាឡើងវិញលើ**សេចក្តីព្រាងច្បាប់ស្តីពីផ្លូវថ្នល់** ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិក អគ្គលេខាធិការរង និងមន្ត្រីនៃក.ស.វ. សមាជិក និងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** មន្ត្រីជំនាញនៃទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងក្រសួងសាធារណការនិងដឹកជញ្ជូន។

សូមរំឭកថា សេចក្តីព្រាងច្បាប់ស្តីពីផ្លូវថ្នល់ បានឆ្លងអង្គប្រជុំជំនាញបច្ចេកទេស នៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០១១។ អង្គប្រជុំពេលនោះបានសម្រេចបង្កើតក្រុមការងារមួយមានសមាសភាព ECOSOCC ក្រុមប្រឹក្សាអ្នកច្បាប់ និងតំណាងក្រសួងសាមី ដើម្បីជួយពិនិត្យកែសម្រួលខ្លឹមសារនៃសេចក្តីព្រាងច្បាប់នេះឡើងវិញ មុនយកមកដាក់ប្រជុំជំនាញបច្ចេកទេសនៅពេលក្រោយទៀត។

អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាឡើងវិញ ហើយបានសម្រេច កែសម្រួលទម្រង់ ខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគ ដើម្បីធ្វើឲ្យសេចក្តីព្រាងនេះកាន់តែល្អ។

អង្គប្រជុំជំនាញបច្ចេកទេសបានបញ្ចប់ការពិភាក្សាលើសេចក្តីព្រាងឯកសារនេះ ដោយទុកជំពូកទី១១ ទោសប្បញ្ញត្តិ ឲ្យក្រសួងសាមីយកទៅពិភាក្សាជាមួយក្រសួងយុត្តិធម៌៕

# ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា ប្រចាំខែវិច្ឆិកា ឆ្នាំ២០១១*

របាយការណ៍ស្ដីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា ប្រចាំខែវិច្ឆិកា ឆ្នាំ២០១១នេះ ជាលទ្ធផលនៃកិច្ចប្រជុំទូលាយក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) នៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១១ ដែលដឹកនាំដោយ ឯកឧត្តម **យឹម ឈុលឡា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិក-សមាជិកា អគ្គលេខាធិការ អគ្គលេខាធិការរង ក.ស.វ. និងតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ។



## ១) ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងអត្រាប្តូរប្រាក់

➡ នាខែវិច្ឆិកានេះ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ថយចុះ ០,៧% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង ៥,៦% បើធៀបនឹងខែដូចគ្នាឆ្នាំមុន (រយៈពេល១២ខែ)។ ការថយចុះនៃសន្ទស្សន៍ថ្លៃខែ**វិច្ឆិកា/តុលា** មានការរួមចំណែករបស់ក្រុមម្ហូបអាហារ ៨៧% និងការដឹកជញ្ជូន ១៤% ។ បើធៀបនឹងខែដូចគ្នាឆ្នាំមុន មានក្រុមទំនិញចំនួនពីរ ដែលមានសន្ទស្សន៍ថ្លៃថយចុះគឺ ទូរគមនាគមន៍ (–១,៦%) និងការកម្សាន្ត និងវប្បធម៌ (–០,៩%)។

| ការឡើងថ្លៃគួរឲ្យកត់សម្គាល់ក្នុងរយៈពេល១២ខែ | |
|---|---|
| *ក្រុមទំនិញ* : | *មុខទំនិញ* : |
| ម្ហូបអាហារ +៦,៤% ការដឹកជញ្ជូន +៧,៦% ភោជនីយដ្ឋាន +៨,៥% និងទំនិញ និងសេវាកម្មផ្សេងៗ +១០%។ | សាច់ជ្រូក +២៥% សាច់គោស្រស់ +១៤% បន្លែ +៦,៤% ឧស្ម័ន +១៥% ប្រេងសាំង +១៤% និងម៉ាស៊ូត +១៨% ។ |

* ការវិភាគជាលាយលក្ខណ៍អក្សរជាការដកស្រង់ចេញពីទិន្នន័យចម្បងៗប៉ុណ្ណោះ មិនគ្របដណ្តប់តួលេខទាំងអស់នៃតារាងទាំង៥ទេ។ ដូច្នេះ អ្នកប្រើប្រាស់ទិន្នន័យអាចទាញយកតួលេខពីតារាងតាមសេចក្តីត្រូវការរៀងខ្លួន។
* ព័ត៌មាន និងតួលេខពណ៌**បៃតង**សំដៅលទ្ធផលល្អប្រសើរ និងពណ៌**ក្រហម**សំដៅលទ្ធផលសម្រាប់ការថ្លឹងថ្លែង។
* ដើម្បីមានសង្គតិភាពក្នុងការប្រើប្រាស់លេខខ្មែរ និងបរទេស សញ្ញាក្បៀសនៅក្នុងអត្ថបទសំណេរតាងឲ្យទសភាគ។ ប៉ុន្តែក្នុងតារាងលេខ (ជា Excel ) សញ្ញាក្បៀសតាងឲ្យខ្ទង់ពាន់ ឯសញ្ញាចុចជាទសភាគវិញ។

**តារាង១.បម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ២០០៩–២០១១**

| ឆ្នាំ | ធៀបនឹង... | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ^P | ប្រចាំឆ្នាំ^P |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០១១ | ខែដូចគ្នាឆ្នាំមុន | ៣,៣% | ៣,៨% | ៣,៨% | ៥,២% | ៦,៥% | ៧,១% | ៧,១% | ៦,៤% | ៦,៧% | ៥,៣% | ៥,៦% | ៥,៦% | ៦,១% |
| | ខែមុន | ០,២% | ០,៧% | ០,៧% | ១,១% | ១,៤% | ០,៥% | ០,៦% | ០,២% | ១,០% | ០,១% | -០,៧% | -០,៨% | |
| ២០១០ | ខែដូចគ្នាឆ្នាំមុន | ៦,៩% | ៧,៣% | ៦,៧% | ៥,៣% | ៤,៥% | ២,៥% | ១,៦% | ១,៧% | ១,៩% | ៣,៦% | ៣,២% | ៧,៣% | ៤% |
| | ខែមុន | ០% | ០,៣% | ០,៦% | -០,៣% | ០,២% | ០% | ០,៥% | ០,៩% | ០,៧% | ១,៤% | –១,០% | –០,២% | |
| ២០០៩ | ខែដូចគ្នាឆ្នាំមុន | ៨,០% | ៦,២% | -០,៧% | -៣,៩% | -៥,៧% | -៤,៨% | -៣,៩% | -២,៩% | -២,៣% | -១,៥% | ១,៣% | ៨,០% | -០,៧% |
| | ខែមុន | -១,៥% | -០,១% | ១,៣% | ១,០% | ១,០% | ១,៩% | ១,៤% | ០,៧% | ០,៥% | -០,៣% | -០,៦% | -០,១% | |

**P:** តួលេខខែធ្នូ និងប្រចាំឆ្នាំ២០១១ ជាតួលេខព្យាករបស់ក.ស.វ. ( តាមវិធីសាស្ត្រ **DECOMPOSITION** )

**ក្រាហ្វ ១. បម្រែបម្រួលថ្លៃទំនិញប្រើប្រាស់ឆ្នាំ២០១០ និង ឆ្នាំ២០១១ ( ធៀបនឹងខែដូចគ្នាឆ្នាំមុន )**




ក្រាហ្វ១ បង្ហាញនិន្នាការបម្រែបម្រួលសន្ទស្សន៍ថ្លៃ (ធៀបនឹងខែដូចគ្នា) ឆ្នាំ ២០១០ និង ២០១១។ ក្រាហ្វនេះក៏បង្ហាញផងដែរ នូវតួលេខព្យាករណ៍ពីរខែទៅមុខនៃអត្រាអតិផរណា (ធៀបនឹងខែដូចគ្នាឆ្នាំមុន)។

➡ **អត្រាប្តូរប្រាក់:**

| *ប្រភេទ* | អត្រាខែវិច្ឆិកា ២០១១ | អត្រាខែតុលា ២០១១ | អត្រាខែវិច្ឆិកា ២០១០ | *ប្រភេទ* | អត្រាខែវិច្ឆិកា ២០១១ | អត្រាខែតុលា ២០១១ | អត្រាខែវិច្ឆិកា ២០១០ |
|---|---|---|---|---|---|---|---|
| **៛/ដុល្លារ** | ៤០៣១៛/១$ | ៤១០០៛/១$ | ៤០៧៥៛/១$ | **បាត/ដុល្លារ** | ៣១,២៥បាត/១$ | ៣០,៤៧បាត/១$ | ៣០,១៩បាត/១$ |
| **៛/បាត** | ១២៩៛/១បាត | ១៣៤៛/១បាត | ១៣៥៛/១បាត | **ដុង/ដុល្លារ** | ២១០០៩ ដុង/១$ | ២០៩៨៦ ដុង/១$ | ១៩៤៩៥ ដុង/១$ |
| **៛/ដុង** | ០,១៩២៛/១ដុង | ០,១៩៥៛/១ដុង | ០,២០៩៛/១ដុង | | | | |

## ២) ស្ថានភាពថវិកាជាតិ

➡យោងតាមស្ថិតិដែលឆ្លងកាត់រតនាគារជាតិ**នាខែវិច្ឆិកា ឆ្នាំ២០១១ ថវិកាជាតិ**មានស្ថានភាពដូចខាងក្រោម:

- ***ចំណូលថវិកាជាតិអនុវត្តបានចំនួន ៥៥០ ពាន់លានរៀល*** *(មធ្យមប្រចាំខែ ៩០% នៃគម្រោង)* ក្នុងនោះ ***ចំណូលមូលធន ៥,២ ពាន់លានរៀល*** *( មធ្យមប្រចាំខែ ៧២% នៃគម្រោង)* និង **ចំណូលចរន្ត ៥៤៥ ពាន់លានរៀល** (មធ្យមប្រចាំខែ ៩១% នៃគម្រោង)។
- បើធៀបនឹងខែមុន **ចំណូលថវិកាជាតិ** កើនឡើង ១៤% និង កើនឡើង ៦% *បើធៀបនឹងខែដូចគ្នាឆ្នាំមុន។* កំណើនក្នុងរយៈពេល១២ខែនេះ ជារួមបណ្តាលមកពីការកើនឡើងនៃចំណូលចរន្ត ១៧% ។

**ក្រាហ្វ ២. ចំណូលថវិកាជាតិ ឆ្នាំ ២០១០ និង ២០១១**



- នៅក្នុងចំណូលចរន្តៈ
  - ✓ ចំណូលសារពើពន្ធ បើធៀបនឹងខែមុន កើនឡើង ១៧% និងកើនឡើង ៣១% ក្នុងរយៈពេល១២ខែ ក្នុងនោះ៖
    - ➢ ពន្ធ និងអាករគយ ថយចុះ ៤% បើធៀបនឹងខែមុន ប៉ុន្តែកើនឡើង ១៦% ក្នុងរយៈពេល១២ខែ
    - ➢ ចំណូលពន្ធដារ ថយចុះ ៩% បើធៀបនឹងខែមុន ប៉ុន្តែកើនឡើង ៣៧% ក្នុងរយៈពេល១២ខែ។
  - ✓ ចំណូលមិនមែនសារពើពន្ធ ថយចុះ ៨% បើធៀបនឹងខែមុន និងថយចុះ ៣៦% បើធៀបនឹងខែដូចគ្នាឆ្នាំមុន។

| **ក្នុងចំណូលសារពើពន្ធ** (ក្នុងវង់ក្រចកៈ បម្រែបម្រួលរយៈពេល ១២ខែ) | | **ក្នុងចំណូលមិនមែនសារពើពន្ធ** (ក្នុងវង់ក្រចកៈ បម្រែបម្រួលរយៈពេល ១២ខែ) | |
|---|---|---|---|
| ➢ ពន្ធ-អាករគយៈ -៤% | (+១៦%) | ➢ នេសាទ : -៧៨% | (-១១%) |
| ➢ ចំណូលពន្ធដារៈ -៩% | (+៣៧%) | ➢ រុក្ខាប្រមាញ់ : -៦៨% | (+២៤%) |
| ➢ ចំណូលសារពើពន្ធផ្សេងៗៈ -១៩% | (-១៤%) | ➢ អាកាសចរណ៍ស៊ីវិល : -២៦% | (-១៨%) |
| ✧ កាស៊ីណូ : -៣៨% | (-៣៥%) | ➢ ផលទុនទេសចរណ៍ : +៤៨% | (+៣៥%) |
| ✧ អាជ្ញាបណ្ណក្នុងស្រុក : -៧៦% | (-៨១%) | ➢ ប្រៃសណីយ៍ និងទូរគមនាគមន៍ : +១៤% | (+៥២៧%) |
| ✧ គ្រប់គ្រង និងទិដ្ឋាការនាំចេញ : +២% | (+១០%) | ➢ អាករស្ថានទូត (លិខិតឆ្លងដែននិងទិដ្ឋាការ) : -១៧% | (+៤%) |

- ***ចំណាយថវិកាជាតិ*** អនុវត្តបាន ៦៧០ ពាន់លានរៀល (*មធ្យមប្រចាំខែ ៧០% នៃគម្រោង*) ក្នុងនោះ **ចំណាយចរន្ត**មានចំនួន ៦១៧ ពាន់លានរៀល (*មធ្យមប្រចាំខែ ១០៥% នៃគម្រោង*) និង**ចំណាយមូលធន**មានចំនួន ៥៣ ពាន់លានរៀល (*ចំណាយមធ្យមប្រចាំខែ ២៦% នៃគម្រោង*) ។

- *បើធៀបនឹងខែមុន* **ចំណាយថវិកាជាតិ** កើនឡើង ៦៤% និងកើនឡើង ៥៨% បើធៀបនឹងខែដូចគ្នាឆ្នាំមុន។ កំណើនខ្ពស់នៃចំណាយថវិកាជាតិក្នុងខែនេះ ជាចំបងបណ្តាលមកពីចំណាយចរន្តកើនឡើង ៧៨% និងបើធៀបនឹងខែដូចគ្នាឆ្នាំមុន ចំណាយចរន្តកើនឡើង ៧៧% ។

- *តុល្យភាពថវិកាជាតិនៃខែវិច្ឆិកាមានឱនភាព ១២០ ពាន់លានរៀល។*

## ៣) ស្ថានភាពរូបិយវត្ថុនិងអត្រាការប្រាក់

➡ ស្ថានភាពរូបិយវត្ថុ ក្នុងខែវិច្ឆិកា ឆ្នាំ ២០១១ មានលក្ខណៈដូចខាងក្រោមៈ

- **រូបិយវត្ថុ** $M_2$ មាន **២២៩៣៧** ពាន់លានរៀល កើនឡើង១,២% ធៀបនឹងខែមុន និងកើនឡើង២០% ក្នុងរយៈពេល ១២ខែ។
- **កំណើន** $M_2$ ធៀបនឹងខែមុន បណ្តាលមកពី ធាតុទាំង៤មានការកើនឡើង ក្នុងនោះ រូបិយវត្ថុក្រៅធនាគារ កើន២% ប្រាក់បញ្ញើចរន្ត កើន១០% ប្រាក់បញ្ញើមានកាលកំណត់និងសន្សំ កើន១៣,៦% និងប្រាក់បញ្ញើជារូបិយប័ណ្ណ កើន០,៧% ។
- យោងតាមតួលេខសមាសធាតុរូបិយវត្ថុ ក្នុងខែនេះ ប្រាក់រៀលសរុប**ក្នុងសេដ្ឋកិច្ច**មានចំនួន ១៨,៩% នៃរូបិយវត្ថុ $M_2$ និងប្រាក់បញ្ញើជារូបិយបណ្ណ មានចំនួន ៨១,១%។

**ក្រាហ្វ៣. សមាសធាតុរូបិយវត្ថុ ខែវិច្ឆិកា ២០១១**



**សមាមាត្រ រវាងចំនួនប្រាក់រៀល និងការផ្គត់ផ្គង់រូបិយវត្ថុ M₂**

| | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ប្រាក់រៀលសរុប នៅក្នុង និងក្រៅធនាគារ | ១៨,៣% | ១៩,១% | ១៩,២% | ១៩,១% | ១៨,៥% | ១៨,០% | ១៧,៦% | ១៧,៨% | ១៨,៤% | ១៨,៤% | ១៨,៩% | |
| ប្រាក់រៀលក្រៅធនាគារ | ១៥,៧% | ១៦,០% | ១៦,៧% | ១៦,៦% | ១៥,៧% | ១៥,២% | ១៤,៩% | ១៤,៩% | ១៥,៦% | ១៥,១% | ១៥,៧% | |

**បម្រែបម្រួលសមាសធាតុរូបិយវត្ថុ ក្នុងខែ វិច្ឆិកា ២០១១ : ក្នុងវង់ក្រចកជា បម្រែបម្រួលរយៈពេល ១២ខែ**




**ទុនបម្រុងជារូបិយបណ្ណបរទេសសុទ្ធ**មានចំនួន **២ ៩៥៥ លានដុល្លារ** កើនឡើង ៥,៣% បើធៀបនឹងខែមុន និងកើនឡើង២០% ក្នុងរយៈពេល ១២ខែ។

***ប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជនៅធនាគារជាតិ*** ជារួម មានការប្រែប្រួលមិនទៀងទាត់។ ក្នុងខែនេះ មានចំនួន **៧ ៣៧៦ ពាន់លានរៀល** កើនឡើង ២% បើធៀបនឹងខែមុន ប៉ុន្តែថយចុះ ១% ក្នុងរយៈពេល ១២ខែ។

***ការផ្តល់ឥណទានដោយធនាគារពាណិជ្ជ*** មានការកើនឡើងជាលំដាប់។ ក្នុងខែនេះ មានចំនួន **១៦ ៩០៤ ពាន់លានរៀល** កើនឡើង ០,៩% បើធៀបនឹងខែមុន និងកើនឡើង៣៤% ក្នុងរយៈពេល ១២ខែ។

***ការផ្តល់ឥណទានដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ*** ក្នុងខែនេះ មានចំនួន **២ ៤៧៦ ពាន់លានរៀល** កើនឡើង ២,២% បើធៀបនឹងខែមុន និងកើនឡើង៤៤% ក្នុងរយៈពេល ១២ខែ។

***អត្រាការប្រាក់ប្រចាំឆ្នាំ នាខែវិច្ឆិកា:***

| *ប្រភេទអត្រាការប្រាក់* | *អត្រា* | *%Δ ធៀបនឹងខែមុន* | *%Δ រយៈពេល១២ខែ* |
|---|---|---|---|
| ▪ បញ្ញើជារៀលនៅធនាគារពាណិជ្ជ | ៦,៤៦% | -០,៩% | –២% |
| ▪ កម្ចីជារៀលនៅធនាគារពាណិជ្ជ | ១៩,៣៤% | +១% | –១៦% |
| ▪ បញ្ញើជាដុល្លារនៅធនាគារពាណិជ្ជ | ៤,៤៣% | +៤% | +១% |
| ▪ កម្ចីជាដុល្លារនៅធនាគារពាណិជ្ជ | ១៤,៩៩% | +១% | –១២% |

## ៤) ស្ថានភាពកសិកម្ម ឧស្សាហកម្ម សេវាកម្ម និងវប្បធម៌

➡ ក្នុងខែវិច្ឆិកា ឆ្នាំ២០១១ ស្ថានភាពផលិតកម្មមានលក្ខណៈដូចខាងក្រោម:

**កសិកម្ម:**

- ✓ ផលិតកម្មនេសាទ មានចំនួន **៤៣ ពាន់តោន** ថយចុះ៤% បើធៀបនឹងខែមុន និងកើនឡើង២៨% ក្នុងរយៈពេល ១២ខែ។

## ឧស្សាហកម្ម:

- ✓ ថាមពលអគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជា មានចំនួន **២២១ GWh** ថយចុះ៣% បើធៀបនឹងខែមុន និងកើនឡើង ១៧% ក្នុងរយៈពេល ១២ខែ។
- ✓ អគ្គិសនីផ្គត់ផ្គង់ដោយវារីអគ្គិសនីមានចំនួន **៧,៩ GWh** ថយចុះ៩% បើធៀបនឹងខែមុន និងកើនឡើង២៩% ក្នុងរយៈពេល ១២ខែ។
- ✓ ផលិតកម្មវាយនភណ្ឌនិងស្បែកជើងមាន ៣៣០ លានដុល្លារ ថយចុះ២១% បើធៀបនឹងខែមុន ប៉ុន្តែកើនឡើង ៣០% ក្នុងរយៈពេល ១២ខែ។
- ✓ ការចុះបញ្ជី ការបើកថ្មី និងការបន្ត រោងចក្រ សហគ្រាសនៅក្រសួងឧស្សាហកម្ម:

| ប្រភេទ | ចំនួន –វិច្ឆិកា២០១១ | ចំនួន–តុលា២០១១ | ចំនួន–វិច្ឆិកា២០១០ |
|---|---|---|---|
| ▪ រោងចក្រថ្មី ដែលបានចុះបញ្ជី | ៥ | ៩ | ៧ |
| ▪ ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បើកថ្មី) | ១០ | ១៥ | ៥ |
| ▪ ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បន្ត) | ១៦ | ១៦ | ៩ |

## សំណង់:

- ✓ **សំណង់អនុញ្ញាតឲ្យសាងសង់** មានចំនួន **១ ៤៨៧ ពាន់ ម²** កើនឡើង២៦១% បើធៀបនឹងខែមុន និងកើនឡើង ៣៩៧% ក្នុងរយៈពេល ១២ខែ។ បើគិតជាសាច់ប្រាក់មានចំនួន **៥៨៨ លានដុល្លារ** កើនឡើង៤៣៣% បើធៀបនឹងខែមុន និងកើនឡើង ៤៨៩% ក្នុងរយៈពេល ១២ខែ។
- ✓ **សំណង់ដែលពេញនិយម** គឺសំណង់ទេសចរ (៧៤% នៃផ្ទៃក្រឡាអនុញ្ញាតសរុប) និងលំនៅឋាន (២០% នៃផ្ទៃក្រឡាអនុញ្ញាតសរុប)។

## ការងារ:

| ប្រភេទ | ចំនួន–វិច្ឆិកា២០១១ | %Δ ធៀបនឹងខែមុន | %Δ រយៈពេល១២ខែ |
|---|---|---|---|
| ការដាក់ពាក្យរកការងារទៅក្រៅប្រទេស | ១ ៣៩២ | -៦០% | -៦០% |
| *អ្នកទទួលបានការងារតាមរយៈក្រសួងការងារ និងក្រុមហ៊ុន* | ៣ ១៥៣ | -៣១% | –៤៥% |
| អ្នកទទួលបានការងារក្នុងប្រទេស | ២ ២៣៦ | 0 | –២៧% |
| អ្នកទទួលបានការងារក្រៅប្រទេស | ៩១៧ | -៦១% | –៦៦% |

## វិនិយោគ:

- ✓ គម្រោងវិនិយោគ**អនុញ្ញាតដោយ** គ.វ.ក./ក.អ.ក. (ថ្មីនិងពង្រីក) ក្នុងខែវិច្ឆិកា មានចំនួន ២០ ដែលគិតជាទុន វិនិយោគស្មើនឹង **៩៦៤ លានដុល្លារ** ។ គម្រោងទាំងនេះអាចបង្កើតការងារឲ្យពលករបាន **៣៣ ពាន់នាក់**។

| ប្រភេទ | វិច្ឆិកា២០១១ | តុលា២០១១ | វិច្ឆិកា២០១០ |
|---|---|---|---|
| **អនុញ្ញាតសរុប (លានដុល្លារ)** | ៩៦៤ | ៣៤៤ | ១០១៧ |
| វិស័យកសិកម្ម និង កសិឧស្សាហកម្ម | ១៧៥ | ២ | ១២ |
| វិស័យឧស្សាហកម្ម | ៤១ | ៩៧ | ៣៣ |
| វិស័យទេសចរណ៍ | ១២ | ២៤៥ | 0 |
| វិស័យហេដ្ឋារចនាសម្ព័ន្ធ និង ផ្សេងៗ | ៤៦៥ | 0 | ៩៧៣ |
| **ចំនួនគម្រោង ថ្មីនិងពង្រីក (ចំនួន)** | ២០ | ១៥ | ១០ |
| **ចំនួនពលករ (ពាន់នាក់)** | ៣៣ | ២៤ | ២៤ |

### សេវាកម្ម និងទេសចរណ៍:

✓**ការចុះបញ្ជី និងលុបចេញពីបញ្ជី នៅក្រសួងពាណិជ្ជកម្ម**

| ប្រភេទ | ចំនួន — វិច្ឆិកា២០១១ | ចំនួន — តុលា២០១១ | ចំនួន—វិច្ឆិកា២០១០ |
|---|---|---|---|
| ▪ ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម | ២២៦ | ២៨៦ | ២១៦ |
| ▪ ក្រុមហ៊ុនត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម | ១ | ៥ | ២ |
| ▪ ក្រុមហ៊ុនដែលបានចុះបញ្ជីបង់ពន្ធដារតាមរបបពិត | ១៩៩ | ២១៨ | ២៧៨ |

✓ **ទំនិញឆ្លងកាត់កំពង់ផែ** (សរុប៦កំពង់ផែ) មានចំនួន ៤០៣ ពាន់តោន កើនឡើង ៣% ធៀបនឹងខែមុន និងកើនឡើង ៣០% ក្នុងរយៈពេល ១២ខែ ក្នុងនោះ៖

| ក្នុងវង់ក្រចក: បម្រែបម្រួលក្នុងរយៈពេល ១២ខែ | | | |
|---|---|---|---|
| ▪ កំពង់ផែភ្នំពេញ : -៩% | (+៧%) | ▪ កំពង់ផែស្រែអំបិល និងកោះកុង : +៣៩% | (+១៦៨%) |
| ▪ កំពង់ផែកំពង់សោម : 0 | (+១៦%) | ▪ កំពង់ផែឧកញ៉ាម៉ុង : -៥៨% | (-៣៣%) |

### ការធ្វើដំណើរតាមផ្លូវអាកាស និងទេសចរណ៍:

| ប្រភេទ | ចំនួន (ពាន់នាក់) | %Δ ធៀបនឹងខែមុន | %Δ រយៈពេល១២ខែ |
|---|---|---|---|
| ▪ ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ | ១១ | +១៤១% | +៩% |
| ▪ អ្នកដំណើរតាមផ្លូវអាកាស (ក្នុងស្រុក) | ១៦ | +៥០% | -៥% |
| ▪ អ្នកដំណើរតាមផ្លូវអាកាស (អន្តរជាតិ) | ៣៤ | -៨៧% | -៨៩% |
| ▪ ចំនួនទេសចរជាតិចេញក្រៅប្រទេស | ៦៦ | +៣% | +៥% |
| ▪ ចំនួនទេសចរអន្តរជាតិមកដល់ព្រះរាជាណាចក្រកម្ពុជា | ២៦៦ | +១៤% | +៦% |
| ✓ តាមផ្លូវអាកាស | ១៤៩ | +២៦% | +៨% |
| ✓ តាមផ្លូវគោក និងទឹក | ១១៦ | +២% | +១២% |

## ៥) ស្ថានភាពជញ្ជីងពាណិជ្ជកម្ម

➡ យោងតាមការកត់ត្រារបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករ **ការនាំចូល**នាខែវិច្ឆិកាមានចំនួន ២ ៣១១ ពាន់លានរៀល បើធៀបនឹងខែមុន កើនឡើង ១% និងកើនឡើង ៣៨% ក្នុងរយៈពេល ១២ខែ ក្នុងនោះ៖

| ទំនិញ | %Δ ធៀបនឹងខែមុន | %Δ ១២ខែ | ទំនិញ | %Δ ធៀបនឹងខែមុន | %Δ ១២ខែ |
|---|---|---|---|---|---|
| ប្រេងសាំង | +៨% | +១២% | ប្រេងម៉ាស៊ូត | –៨% | –៥% |
| ប្រេងខ្មៅ | +១៣៩% | +១៦% | ឧស្ម័ន | –៣% | +១១% |
| ស៊ីម៉ង់ត៍ | +៣% | –៥% | ដែកសំណង់ | –៥៨% | –៣៦% |
| រថយន្តសរុប (ព.ល.រ) | +១៧% | +៣១% | ត្រាក់ទ័រនិងគោយន្ត (គ្រឿង) | –៣៦% | –៧៣% |
| រថយន្តសរុប (គ្រឿង) | +១១% | +២៧% | ជីនិងថ្នាំកសិកម្ម | –៣៣% | –៧% |
| គ្រឿងអេឡិចត្រូនិក (គ្រឿង) | –៤០% | –២២% | ការនាំចូលក្នុងក្របខណ្ឌច្បាប់វិនិយោគ | –១១% | +៣២% |
| ម៉ូតូ (គ្រឿង) | –៤៤% | –៥៣% | | | |

➡ **ការនាំចេញ** ក្នុងខែវិច្ឆិកា ឆ្នាំ២០១១ មានចំនួន ១ ៥៦៨ ពាន់លានរៀល (៦៨% នៃការនាំចូល) ថយចុះ ៥% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង ៣១% ក្នុងរយៈពេល ១២ខែ ក្នុងនោះ មុខទំនិញសំខាន់ៗមួយចំនួនមាន៖

| ទំនិញ | %Δធៀបនឹងខែមុន | %Δ ១២ខែ | ទំនិញ | %Δធៀបនឹងខែមុន | %Δ ១២ខែ |
|---|---|---|---|---|---|
| ផលិតផលនេសាទ | +១៥% | +៥៥% | ផលិតផលឈើកែច្នៃ | +៩៨% | –៩២% |
| អង្ករ | +៣% | +២៤៦% | វាយនភណ្ឌនិងស្បែកជើង | –៧% | +២៥% |
| កៅស៊ូ | –១៥% | +១២% | | | |

➡ ក្នុងខែវិច្ឆិកានេះ ជញ្ជីងពាណិជ្ជកម្មមាន*ឱនភាពចំនួន ៧៤៣ ពាន់លានរៀល ស្មើនឹង ១៨៦ លានដុល្លារ ស.រ.អ.។*

## ៦) បម្រែបម្រួលគួរឲ្យចាប់អារម្មណ៍

ក្នុងខែវិច្ឆិកា ឆ្នាំ២០១១នេះ សូចនាករសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៃព្រះរាជាណាចក្រកម្ពុជា បង្ហាញបម្រែបម្រួលគួរឲ្យចាប់អារម្មណ៍ដូចខាងក្រោម:

| ល.រ. | សូចនាករ | ធៀបនឹងខែមុន | រយៈពេល១២ខែ | កំណត់សម្គាល់ |
|---|---|---|---|---|
| ១ | ថ្លៃសាច់ជ្រូក | -២,៦% | +២៥% | ការផ្គត់ផ្គង់ក្នុងស្រុកនៅមានកម្រិតទាប |
| ២ | អត្រាប្តូរប្រាក់ (រ/បាត) | -៣,៧% | -៤,៤% | — |
| ៣ | ចំណូលពីកាស៊ីណូ | -៣៨% | -៣៥% | — |
| ៤ | កម្ចីទិញផ្ទះជាកម្មសិទ្ធិផ្ទាល់ខ្លួន | +០,៩% | +១៣៣% | ១) អំណាចទិញរបស់អ្នកប្រើប្រាស់កើនឡើង<br>២) មានគោលនយោបាយឲ្យខ្ចីរបស់ធនាគារពាណិជ្ជ |

## ៧) ស្មារតីអង្គប្រជុំ និងការសន្និដ្ឋាន

***អង្គប្រជុំបានពិភាក្សាបញ្ហាសំខាន់ គួរឲ្យចាប់អារម្មណ៍ដូចខាងក្រោម:***

១) ទោះបីក្នុងខែវិច្ឆិកា ឆ្នាំ២០១១ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់មានការថយចុះធៀបនឹងខែមុនក៏ដោយ ក៏ប៉ុន្តែសន្ទស្សន៍ថ្លៃតែងតែមានកម្រិតខ្ពស់ក្នុងដើមឆមាសទី២ បើធៀបនឹងឆមាសទី១។ ដូច្នេះហើយក្នុងខែនាចុងឆ្នាំ យើងតែងតែសង្កេត ឃើញសន្ទស្សន៍ថ្លៃមានការថយចុះ ធៀបនឹងខែមុន ដែលជាការចាប់ផ្តើមនិន្នាការថយចុះនៃកំណើនសន្ទស្សន៍ថ្លៃក្នុងឆមាសទី១ ឆ្នាំ២០១២។

២) អតិផរណាក្នុងខែវិច្ឆិកា (បម្រែបម្រួលសន្ទស្សន៍ថ្លៃធៀបនឹងខែវិច្ឆិកាឆ្នាំមុន) មានអត្រា ៥,៦% ដែលជាចំបងបណ្តាលមកពីការឡើងថ្លៃនៃក្រុមម្ហូបអាហារ ដែលនៅក្នុងនោះ មុខទំនិញដែលគួរឲ្យចាប់អារម្មណ៍មាន អង្ករ សាច់គោ សាច់ជ្រូក និងបន្លែ។

***សេចក្តីសន្និដ្ឋាន:***

អត្រាអតិផរណាឆ្នាំ ២០១១ អាចមានកម្រិតក្រោម ៦% ដែលលើសពីផែនការគ្រប់គ្រងអតិផរណា (៥% ប្រចាំឆ្នាំ)។ យ៉ាងណាក្តី យោងតាមព្រឹត្តិការណ៍ដែលបានកើតឡើងក្នុងឆ្នាំកន្លងមក អត្រា៦%នេះ ជាលទ្ធផលនៃការខិតខំប្រឹងប្រែងមួយ ក្នុងការគ្រប់គ្រងថ្លៃទំនិញប្រើប្រាស់។ ក្រុមម្ហូបអាហារមានការរួមចំណែកធំជាងគេទៅលើអតិផរណា និន្នាការនេះនឹងបន្តក្នុងសកលលោកក្នុងរយៈពេលវែង។ ដូច្នេះកសិកម្មគឺជាវិស័យអាទិភាពយូរអង្វែងសម្រាប់ប្រទេសកម្ពុជា។

យោងតាមតួលេខគម្រោងវិនិយោគអនុញ្ញាតដោយ គ.រ.ក./ក.អ.ក. ទុនវិនិយោគដែលហូរចូលក្នុង វិស័យកសិកម្ម និង កសិឧស្សាហកម្ម រយៈពេល ១១ខែឆ្នាំ២០១១នេះ មានចំនួនតែ ៧% នៃទុនវិនិយោគដែលបានអនុញ្ញាតសរុបប៉ុណ្ណោះ ដូច្នេះការពង្រីក និងទំនើបកម្មវិស័យនេះ ពិតជានៅមានកម្រិតខ្លាំងណាស់៕

# សកម្មភាពផ្សេងទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមករា ឆ្នាំ២០១២

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០៦/០១/១២<br>ម៉ោង ០៧ : ៣០ នាទី | ចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការនូវ ស្ពានអាកាស ៧ មករា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត នៅតាមបណ្តោយមហាវិថីសហព័ន្ធរុស្ស៊ី(ស្តុបពេទ្យលោកសង្ឃ)។ |
| ២ | ០៧/០១/១២<br>ម៉ោង ០៨ : ០០ នាទី | ចូលរួមជាកិត្តិយសក្នុងពិធីមិទ្ទិញអបអរសាទរខួបអនុស្សាវរីយ៍លើកទី ៣៣ នៃទិវាជ័យជំនះ ៧ មករា (១៩៧៩-២០១២) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ នៅទីធ្លាមុខមន្ទីរគណបក្សប្រជាជនកម្ពុជា ខេត្តតាកែវ។ |
| ៣ | ០៧/០១/១២<br>ម៉ោង ១៤ : ០០ នាទី | ចូលរួមជាកិត្តិយសក្នុងកិច្ចប្រជុំក្រុមការងារ ដើម្បីធ្វើការណែនាំអំពីផែនការរួមឆ្ពោះទៅកាន់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់អាណត្តិទី៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅមន្ទីរគណបក្សប្រជាជនកម្ពុជា ខេត្តតាកែវ។ |
| ៤ | ១១/០១/១២<br>ម៉ោង ១៦ : ០០ នាទី | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើៈ<br>១-សេចក្តីព្រាងកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល ២០១២-២០១៤។<br>២-សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា។<br>៣-សេចក្តីព្រាងសារាចរណែនាំស្តីពីការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រ នៃព្រះរាជាណាចក្រកម្ពុជា។<br>៤-បញ្ហាផ្សេងៗ។<br>ដើម្បីត្រៀមប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៥ | ១២/០១/១២<br>ម៉ោង ០៩ : ៣០ នាទី | ជាអធិបតីភាពក្នុងកិច្ចប្រជុំវាយតម្លៃ និងប្រគល់-ទទួលអគារសារមន្ទីរវាយនតណ្ឌប្រពៃណីអាស៊ី នៅបុរីវប្បធម៌ និងទេសចរណ៍-អង្គរ ជូនអាជ្ញាធរអប្សរា នៅបុរីវប្បធម៌ និងទេសចរណ៍-អង្គរ ខេត្តសៀមរាប។ |
| ៦ | ១២/០១/១២<br>ម៉ោង ១៤ : ០០ នាទី | ជាអធិបតីភាពក្នុងកិច្ចប្រជុំវាយតម្លៃ និងប្រគល់-ទទួលបញ្ចប់នៃគម្រោងដាក់បង្គោលភ្លើងបំភ្លឺផ្លូវ និងស្តារឡើងវិញនូវប្រព័ន្ធអគ្គិសនី និងប្រគល់-ទទួលគម្រោងជួសជុលពង្រីកផ្លូវចាក់កៅស៊ូ DBST ផ្លូវកូម៉ែ ក្រោយសុពលភាពនៃការធានាគុណភាព នៅផ្លូវកូម៉ែ ខេត្តសៀមរាប។ |

# សកម្មភាពផ្សេងទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមករា ឆ្នាំ២០១២ (ត)

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ៧ | **១៣/០១/១២ ម៉ោង ០៨:៣០នាទី** " | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈ ដូចខាងក្រោម:<br>១-សេចក្តីព្រាងកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល ២០១២-២០១៤។<br>២-សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា។<br>៣-សេចក្តីព្រាងសារាចរណែនាំស្តីពីការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រ នៃព្រះរាជាណាចក្រកម្ពុជា។<br>៤-បញ្ហាផ្សេងៗ។<br>នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ៨ | **១៧/០១/១២ ម៉ោង ០៨:០០នាទី** | ចូលរួមជាកិត្តិយសក្នុងពិធីបិទការប្រកួតកីឡាប៉េតង់ ពានរង្វាន់ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី បណ្ឌិតសភាចារ្យ **សុខ អាន** ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីលានប៉េតង់ពហុកីឡាដ្ឋានជាតិ។ |
| ៩ | **២០/០១/១២ ម៉ោង ១៦:០០នាទី** | ជួបប្រជុំពិភាក្សាការងារជាមួយ ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១០ | **២៣/០១/១២ ម៉ោង ១០:០០នាទី** | ចូលរួមគោរពវិញ្ញាណក្ខន្ធ ឯកឧត្តម **ខាត់ សុទ្ធ** នៅគេហដ្ឋានរបស់សព។ |
| ១១ | **២៣/០១/១២ ម៉ោង ១៥:៣០នាទី** | ជួបប្រជុំពិភាក្សាការងារជាមួយ លោកវិស្វករប្រធានបច្ចេកទេស SCA នៅបន្ទប់ ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១២ | **២៦/០១/១២ ម៉ោង ៩:០០នាទី** | ប្រជុំការងារជាមួយ ឯកឧត្តម អគ្គលេខាធិការ ស្តីពីការពិនិត្យតែងតាំងមន្ត្រីអគ្គលេខាធិការដ្ឋាន នៅបន្ទប់ ឯកឧត្តម ប្រធាន ECOSOCC នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៣ | **២៦/០១/១២ ម៉ោង ១៥:០០នាទី** | ចូលរួមប្រជុំគណៈកម្មការព្រលានយន្តហោះ នៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ។ |
| ១៤ | **២៧/០១/១២ ម៉ោង ០៩:០០នាទី** | ជួបប្រជុំពិភាក្សាការងារជាមួយ លោក Kim Chon Song អ្នកគ្រប់គ្រងក្រុមហ៊ុនម៉ាន់ស៊ូដេញតិច នៅបន្ទប់ ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |

# សកម្មភាពដទៃទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមករា ឆ្នាំ២០១២ (តចប់)

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១៥ | ៣០/០១/១២<br>ពេញមួយថ្ងៃ | ដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដើម្បីពិនិត្យ និងពិភាក្សាលើៈ<br>១-បូកសរុបការងារប្រចាំឆ្នាំ២០១១ និងលើកទិសដៅការងារឆ្នាំ២០១២។<br>២-បញ្ហាផ្សេងៗ។<br>នៅទីស្តីការគណៈរដ្ឋមន្ត្រី ។ |
| ១៦ | ៣១/០១/១២ ម៉ោង<br>១៥:៣០នាទី | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើៈ<br>១-សេចក្តីព្រាងរបាយការណ៍ពាក់កណ្តាលអាណត្តិឆ្នាំ២០១១ ស្តីពីការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣។<br>២-សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត។<br>៣-សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការបង្កើតបញ្ញត្តិករទូរគមនាគមន៍កម្ពុជា។<br>៤-បញ្ហាផ្សេងៗ។<br>ដើម្បីត្រៀមប្រជុំត្រួតពិនិត្យជាចុងក្រោយ ជាមួយ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី ។ |





រូបភាពក្នុងកិច្ចប្រជុំស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជាប្រចាំខែវិច្ឆិកា ឆ្នាំ២០១១

# សកម្មភាពផ្សេងទៀតរបស់ ឯកឧត្តម អនុប្រធាន សមាជិក និង អគ្គលេខាធិការ ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមករា ឆ្នាំ២០១២

## ឯកឧត្តម យឹម ណុលសន អនុប្រធាន

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០៧/០១/១២ | ចូលរួមជាកិត្តិយសក្នុងពិធីមិទ្ទិញអបអរសាទរខួបអនុស្សាវរីយ៍លើកទី៣៣ នៃទិវាជ័យជំនះ ៧មករា (១៩៧៩-២០១២) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ នៅទីធ្លាមុខមន្ទីរគណបក្សប្រជាជនកម្ពុជា ខេត្តតាកែវ។ |

## ឯកឧត្តម ឡុង ឈាង សមាជិក

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ១១/០១/១២ | ចូលរួមប្រជុំពិភាក្សាឆ្លងសេចក្តីព្រាងរបាយការណ៍ស្តីពីសកម្មភាព និងលទ្ធផលការងារប្រចាំឆ្នាំ២០១១ របស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី(អ.ជ.ដ.)។ |

## ឯកឧត្តម ង៉ាន់ ភិរុណ អគ្គលេខាធិការ

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ១៣/០១/១២<br>" | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈ ដូចខាងក្រោម:<br>១-សេចក្តីព្រាងកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល ២០១២-២០១៤។<br>២-សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា។<br>៣-សេចក្តីព្រាងសារាចរណែនាំស្តីពីការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រ នៃព្រះរាជាណាចក្រកម្ពុជា។<br>៤-បញ្ហាផ្សេងៗ។<br>នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ២ | ១៧/០១/១២ | ចូលរួមជាកិត្តិយសក្នុងពិធីបិទការប្រកួតកីឡាប៉េតង់ ពានរង្វាន់ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី បណ្ឌិតសភាចារ្យ សុខ អាន** ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីលានប៉េតង់ពហុកីឡាដ្ឋានជាតិ។ |

# ព្រឹត្តិបត្រព័ត៌មាន

| | | |
|---|---|---|
| នាយកគ្រប់គ្រងទូទៅ: | **ឯកឧត្តម គីម សយសាម៉ាឡៃន** | អនុប្រធាន ក.ស.វ. |
| និពន្ធនាយក: | **ឯកឧត្តម ចាន់ តិរុណា** | អគ្គលេខាធិការ ក.ស.វ. |
| និពន្ធអគ្គបទ: | **ឯកឧត្តម អេង វត្ថមុនី** | អគ្គលេខាធិការរង ក.ស.វ. |
| វិភាគស្ថានភាពសេដ្ឋកិច្ច: | **ឯកឧត្តម ម៉ម សារិទ្ធ** | សមាជិកបម្រុង ក.ស.វ. |
| ទំនាក់ទំនងនិងបោះពុម្ពផ្សាយ: | **លោក ម៉ក់ ឆារ៉ា** | ប្រធានផ្នែក ក.ស.វ. |
| បច្ចេកទេសកុំព្យូទ័រនិងសម្របសម្រួល: | **លោក សយ វាស្នា** | អនុប្រធានផ្នែក ក.ស.វ. |
| យកព័ត៌មាននិងថតរូប: | **លោក មុត ភក្ដដា** | មន្ត្រី ក.ស.វ. |



## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌


ទូរស័ព្ទលេខ: ០២៣ ២១១ ៩៤៣ ០១៦ ៣០៧ ៣៣០

ទូរសារលេខ: ០២៣ ២១១ ៩៤៣

E-mail: veasna@live.in